# ស្រឹងប៉ាវចិន / Tingid Bug

*Diconocoris hewetti and D.distanti*





រូបភាព៖ PlantVillage



រូបភាព៖ CABI



រូបភាព៖ PlantVillage

## ១. លក្ខណៈទូទៅ

សត្វល្អិតប្រភេទនេះ ធ្វើការបំផ្លាញទៅលើទៅលើចង្កោមផ្លែ ដែលបណ្តាលអោយស្ងួតងាប់កោសិកានៃចង្កោមផ្លែនោះ ហើយក៏បណ្តាលអោយម្រេចដាក់គ្រាប់មិនពេញល្អ និងមានស្នាមងាប់កោសិការនៅលើស្លឹកផងដែរ។

| មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | | | |

មានការបំផ្លាញច្រើន

មានវត្តមាន




## ២. វដ្តជីវិត

សត្វពេញវ័យរបស់វាមានពណ៌ខ្មៅ មានស្លាបទំហំប្រមាណ ៤.៥ x ៣.០ម.ម និងមានស្នែងមួយគូរស្ថិត នៅត្រង់ផ្នែកប្រអប់ទ្រូង។ វាទំលាក់ពងដាច់ដោយឡែកពីគ្នានៅលើចង្កោមផ្លែ។ វគ្គជង្គូវរបស់វាមាន ៥ដំណាក់កាល និងមានបន្លាពាសពេញសារពាង្គកាយ។ ដំណាក់កាលពង និងដក់ដឿរបស់វាមានរយៈពេលប្រមាណពី ១០-១៩ថ្ងៃ ហើយសត្វពេញវ័យរបស់វារស់បានរយៈពេល ២៧ថ្ងៃ។ ប្រជាករដែលខ្ពស់បំផុតរបស់សត្វប្រភេទនេះ ស្ថិតនៅក្នុងកំឡុងខែតុលា ដល់ខែកុម្ភៈ ដែលជាពេលវេលានៃការចេញផ្លែផ្ការបស់ម្រេច។

រៀបចំដោយ៖ នាយកដ្ឋានការពារដំណាំ អនាម័យ និងភូតគាមអនាម័យ នៃអគ្គនាយកដ្ឋានកសិកម្ម
ឧបត្ថម្ភដោយ៖ គម្រោងជំរុញសុវត្ថិភាពចំណីអាហារ ខ្សែច្រវាក់តម្លៃដំណាំម្រេច និងការបើកទីផ្សារក្នុងប្រទេសវៀតណាម ឡាវ និងកម្ពុជា (STDF/PG/619)

## ៣. ការអង្កេតតាមដាន

ការបំផ្លាញមានសកម្មភាពខ្លាំងចាប់ពីពេលម្រេចចេញផ្កាទៅ រហូតដល់ដំណាក់កាលម្រេចចេញក្តឹប។ ការអង្កេតវត្តមានស្រឹងប៉ាវចិន ត្រូវពិនិត្យនៅលើផ្កា ឬក្តួរម្រេចខ្ចីៗ នៅពេលព្រឹកព្រលឹម។ ដំណាក់កាលកូន និងពេញវ័យនៃស្រឹងប៉ាវចិន គឺជាដំណាក់កាលដែលបំផ្លាញដំណាំម្រេចខ្លាំង។

ផ្កាម្រេចដែលរងការបំផ្លាញដោយស្រឹងប៉ាវចិន នឹងប្រែពណ៌ពីត្នោតទៅខ្មៅត្រង់ចំណុចដែលស្រឹងប៉ាវចិនជញ្ជក់។ ផ្កា ឬក្តឹបដែលរងការបំផ្លាញនឹងប្រែជាស្រពោន មានពណ៌ប្រផេះ រួចជ្រុះនៅពេលមានការបំផ្លាញខ្លាំងក្លា។











## ៤. វិធានការគ្រប់គ្រង និងកម្ចាត់

- ថែរក្សាពពួកសត្វសរីរាង្គមានប្រយោជន៍ដែលស៊ីចៃកប៉ាល់ហោះ ដូចជាកន្ទុំរុយ ពពួកពីងពាង សត្វកន្ទុយពីរ កណ្តូបបុកស្រូវក៏ដូចជាសត្វបង្គួយជីងចក់ជាដើម។
- ធ្វើការត្រួតពិនិត្យជាប្រចាំ និងដោយយកចិត្តទុកដាក់ អំពីវត្តមាន និងប្រជាកររបស់ចៃកប៉ាល់ហោះ នៅក្នុងរដូវដែលមានការបំផ្លាញខ្លាំង គឺចាប់ពីម្រេចចេញផ្ការហូតដល់ម្រេចដាក់គ្រាប់ ដោយការសង្កេតគួរធ្វើនៅពេលព្រឹកព្រលឹម។
- ចាប់ដោយដៃ និងកម្ទេចសត្វពេញវ័យ និងកូនចៃកប៉ាល់ហោះពីផ្កា និងពីផ្លែម្រេច នៅពេលដែលសត្វល្អិតមានចំនួនតិចនៅឡើយ។
- ប្រើថ្នាំពុលផ្សំពីរុក្ខជាតិ មានថ្នាំខ្លាំង ២-៥គីឡូក្រាម មើមក្តួច ៣-៥គីឡូក្រាម និងល្ងាសៀម ២-៥គីឡូក្រាម ដោយត្រាំជាមួយទឹក ៦០លីត្រ រយៈពេល ៥-១០ថ្ងៃ ទើបយកទៅបាញ់លើចៃកប៉ាល់ហោះ។
- ក្នុងករណីប្រើថ្នាំពុលផ្សំពីរុក្ខជាតិមិនមានប្រសិទ្ធិភាព អាចប្រើថ្នាំអាសេហ្វាត (Acephate)[១] ឈ្មោះលក់នៅទីផ្សារ មោនស្ទ័រ (Monster) ក្នុងកម្រិត ១៥ម.ល[២] លាយទឹក ១០លីត្រ (អាចប្រមូលផល ក្រោយពេលបាញ់បាន ១០-១៥ថ្ងៃ) ឬប្រើថ្នាំប៊ុយប្រូហ្វេស៊ីន (Buprofezin)[៣] ឈ្មោះលក់លើទីផ្សារ ប៊ុយទីល និងអាប់ផ្លូដ (Butyl 10WP and Applaud 10WP) ក្នុងកម្រិត ២០ក្រាម លាយទឹក ៨លីត្រ (អាចប្រមូលផលបានក្រោយពេលបាញ់ថ្នាំ ៧ថ្ងៃ) ឬប្រើថ្នាំឌីណូតេហ្វូយ៉ាន (Dinotefuran)[៤] ឈ្មោះលក់លើទីផ្សារ អូស៊ីន (OSHIN 20WP) ក្នុងកម្រិត ១កញ្ចប់តូច ៦,៥ក្រាម លាយទឹក ១៦លីត្រ (អាចប្រមូលផលក្រោយពេលបាញ់បាន ៧ថ្ងៃ)។

១ ថ្នាំពុលក្នុងចំណាត់ថ្នាក់ទី៣ (ចំណាត់ថ្នាក់អង្គការសុខភាពពិភពលោក)
២ មួយមីល្លីលីត្រ = មួយសេសេ
៣ ថ្នាំពុលក្នុងចំណាត់ថ្នាក់ទី៤ (Un) (ចំណាត់ថ្នាក់អង្គការសុខភាពពិភពលោក)
៤ ថ្នាំពុលក្នុងចំណាត់ថ្នាក់ទី៣ (ចំណាត់ថ្នាក់យោងតាមព្រឹត្តប័ត្រពត៌មាន ភ្នាក់ងារការពារបរិស្ថាន EPA សហរដ្ឋអាមេរិក)

រៀបចំដោយ៖ នាយកដ្ឋានការពារដំណាំ អនាម័យ និងភូតគាមអនាម័យ នៃអគ្គនាយកដ្ឋានកសិកម្ម
ឧបត្ថម្ភដោយ៖ គម្រោងជំរុញសុវត្ថិភាពចំណីអាហារ ខ្សែច្រវាក់តម្លៃដំណាំម្រេច និងការបើកទីផ្សារក្នុងប្រទេសវៀតណាម ឡាវ និងកម្ពុជា (STDF/PG/619)